**Declassified to Public**
**06 September 2012**

D34/I

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត

| | | |
|---|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ: | | ០០២/១៩-០៩-២០០៦ អវតក/កសព |
| លេខស៊ើបសួរ | : | ០០១/១៨-០៧-២០០៧ អវតក/កសចស |
| ឈ្មោះសំណុំរឿង | : | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ |
| បញ្ជូនទៅ | : | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទនៃការបញ្ជូន | : | ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន | : | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | : | ភាសាខ្មែរ |
| ប្រភេទឯកសារ | : | សម្ងាត់ |

---

# ករណីបញ្ជូនបណ្តឹង
# របស់លោក សក្ក: រត្តនាបឆាតទ្រង់ដែងខ្មៅ ចុះថ្ងៃទី ១១-០១-២០០៧

---

**បញ្ជូនដោយ៖**

**សហព្រះរាជអាជ្ញា ៖**

លោកស្រី ជា លាង

Mr. Robert PETIT

**បញ្ជូនទៅ៖**

**សហចៅក្រមស៊ើបអង្កេត ៖**

លោក យូ ប៊ុនឡេង

Mr. Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ORIGINAL DOCUMENT
RECEIVED ON 09/04/2008
AT 11:20' BY
NUP SOTHUNVLEHET
ACTING CASE FILE OFFICER

00158066

D34/I

## ក.សេចក្ដីផ្ដើម នៃប្រវត្តិនីតិវិធី

១. ពាក្យបណ្ដឹងរបស់លោក សក្ករៈ រត្តនាបនាតទ្រង់ដែងរង្សី ចុះថ្ងៃទី ១១-០១-០៧ ការិយាល័យសហព្រះរាជអាជ្ញា បានបញ្ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៤-០៨-០៦ ហើយបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

២. នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងតាមដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ មកការិយាល័យសហព្រះរាជអាជ្ញា ហើយបានបញ្ជាក់ថា មានពាក្យបណ្ដឹងមួយក្នុងចំណោមពាក្យបណ្ដឹងទាំងនោះ ទំនងជាមិនអាចទទួលយកបានឡើយ ពីព្រោះវាមិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

៣. ក្រោយពីបានពិនិត្យ ពិចារណាលើសំណុំរឿងទាំងនោះសារជាថ្មី សហព្រះរាជអាជ្ញាយល់ឃើញថា ពាក្យបណ្ដឹងរបស់លោក សក្ករៈ រត្តនាបនាតទ្រង់ដែងរង្សី ចុះថ្ងៃទី ១១-០១-២០០៧ មិនស្ថិតក្នុងដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ។

## ខ-សំណើ

៤. ស្នើសហចៅក្រមស៊ើបអង្កេត ធ្វើការបំបែកពាក្យបណ្ដឹងរបស់លោក សក្ករៈ រត្តនាបនាតទ្រង់ដែងរង្សី ចុះថ្ងៃទី ១១-០១-២០០៧ ចេញពីសំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៤-០៨-០៦ ហើយបញ្ជូនពាក្យបណ្ដឹងនេះមកការិយាល័យសហព្រះរាជអាជ្ញាវិញ ដើម្បីយើងខ្ញុំធ្វើការសំរេចលើពាក្យបណ្ដឹងនោះសារជាថ្មីតាមនីតិវិធី ។

សូមលោកចៅក្រមទទួលនូវសេចក្ដីគោរពរាប់អាន អំពីយើងខ្ញុំ ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៨

**សហព្រះរាជអាជ្ញា**
**Co-Prosecutors**

ជា លាង Robert PETIT

00158067



# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## ការិយាល័យសហចៅក្រមស៊ើបអង្កេត

ជូនចំពោះ៖ សហព្រះរាជអាជ្ញានៃអវតក

ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨

យោង ៖ លិខិតឆ្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០០៨

ពី ៖ លោក យូ ប៊ុនឡេង
លោក Marcel LEMONDE
**សហចៅក្រមស៊ើបអង្កេត**

កម្មវត្ថុ ៖ ការបញ្ជូនពាក្យបណ្តឹងរបស់លោក សក្តរៈ វត្តនាបឆាតទ្រង់ដែងរង្សី ចុះថ្ងៃទី១១ ខែមករាឆ្នាំ២០០៧

ជាការឆ្លើយតបនឹងចម្លើយរបស់លោក-លោកស្រីសហព្រះរាជអាជ្ញាចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ សូមលោក-លោកស្រីសហព្រះរាជអាជ្ញា ទទួលយកនូវពាក្យបណ្តឹងរបស់លោក សក្តរៈ វត្តនាបឆាតទ្រង់ដែងរង្សី ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៨ ដែលមានភ្ជាប់មកជាមួយនេះ។

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
15 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA